សរសេរដោយ ឧប សៅ សង្ហា

# ទស្សនវិទូល្បីៗ និង ទ្រឹស្តីសំខាន់ៗ



# មាតិការឿង

សេចក្តីផ្តើម 1
អាឡាំង Alain (1868-1951) 4
អារីស្តូត Aristote (384-322 av.J-c) 8
ប៊ែរសុន Bergson (1859-1941) 17
អារម្ភកថា 28




# សេចក្តីផ្តើម

នៅទីនេះ យើងលើកយក ទស្សនវិទូល្បីៗមួយចំនួន និង ទ្រឹស្តីសំខាន់ៗ មកបង្ហាញ ជាឈុត នៃការសិក្សា។

ត្រូវដឹងថា ទស្សនវិជ្ជា វាគ្មាននៅក្នុងវប្បធម៌ខ្មែរនោះទេ។ នៅពេលបារាំង គេមកត្រួតស្រុកខ្មែរ គេបានបញ្ចូលមុខវិជ្ជានេះ នៅក្នុងកម្មវិធីសិក្សាទំនើបខ្មែរ តែយុវជនខ្មែរ នៅសម័យនោះ មិនសូវ ចាប់អារម្មណ៍នឹងមុខវិជ្ជានេះ ឡើយ ហើយថែមទាំង ចំអកលេងថា ជាវិជ្ជាសំរាប់មនុស្ស ឆ្កួតទៅទៀត ព្រោះនាំគ្នាសិក្សាទៅលើអ្វីៗ ដែលគ្មានរូប ហើយយកវាមកជជែកវែកញែក រកសេចក្តីពិត។ តែខ្មែរ ជាអ្នកកាន់ពុទ្ធសាសនា មិនបានចាំអារម្មណ៍ថា នៅក្នុង សិក្ខាបទ នៃព្រះដ៏មានព្រះភាគ ក៏មានលក្ខណៈ ជាការ ពិចារណាទៅលើ វត្ថុឥតរូបជាច្រើន, ធម្មជាតិ និង ទៅលើ ធាតុជាមនុស្ស ដែលព្រះអង្គទុកជាសត្វបញ្ញា (បញ្ញា ជា សភាវៈដឹងដោយពិសេស)។ បញ្ញានេះឯង ជាដួង នៃទស្ស វិជ្ជា។ គ្មានបញ្ញា គឺគ្មានមនុស្សលោកនោះឡើយ ដូច្នេះ ដើម្បីអោយសត្វមនុស្ស ក្លាយជាមនុស្ស មនុស្សត្រូវការ មានការអប់រំចិត្ត អោយមានបញ្ញា ព្រោះមនុស្សមានបញ្ញា

ត្រូវប្រកបដោយ សេចក្តីឆ្លាត បីយ៉ាង : គឺស្គាល់ អ្វីដែលនាំអោយវិនាស, ឆ្លាតក្នុងសេចក្តីចំរើន និង ឆ្លាតក្នុងឧបាយ គឺ វិធីចេញអោយផុតពីសេចក្តីវិនាស និង វិធីធ្វើអោយបានសម្រេចនូវសេចក្តីចំរើន[1]។

ដោយសារ ទស្សនវិជ្ជា វាគ្មាននៅក្នុងចំណេះដឹងខ្មែរ ដូច្នេះ វាមានការពិបាកនឹងប្រើវាក្យសព្ទខ្មែរ អោយចំ អត្ថន័យពិតនឹងវាក្យសព្ទ ទស្សនវិជ្ជា។ ការណ៍នេះ ក៏មាននៅក្នុងការយល់ដឹងអំពីទស្សនៈជាជម្រៅ នៃទស្សនវិជ្ជានោះដែរ។ ដូច្នេះនៅទីនេះ យើងសាកល្បង សម្មត នូវវាក្យសព្ទទស្សនវិជ្ជា យកមកប្រើ ជាភាសាខ្មែរសាមញ្ញ ដើម្បីស្រួលយល់ នូវនិយមន័យ និង ទស្សនៈ របស់វា។ ត្រូវដឹងថា នៅក្នុងពុទ្ធសាសនា ទុកសត្វលោកទាំងអស់ រួមទាំងមនុស្សយើងផងច្រើនមានសំគាល់ថា ក្នុងរូបកាយមនុស្ស មានអ្វីដែលហៅថា អត្តា (ព្រលឹង) ជារបស់ទៀងទាត់ស្ថិតស្ថេរ។ ប៉ុន្តែព្រះសម្មាសម្ពុទ្ធ បានជ្រាបច្បាស់ថា ក្នុងរូបកាយរបស់មនុស្ស

[1] ដកស្រង់ពីសៀវភៅរៀបរៀងដោយ ភិក្ខុ ងឹន ភេន ឥន្ទបញ្ញោ : ដៃគូមនុស្ស។

គ្មានអ្វីដែលហៅថា អត្តានោះទេ។ រូបកាយរបស់យើងគឺ ខន្ធ៥ តែប៉ុណ្ណោះ គ្មានអ្វីក្រៅពីនេះទៀតទេ។ ខន្ធ ៥ គឺ វេទនា សញ្ញាសង្ខារវិញ្ញាណ។ រូប គឺ រូបកាយទាំងមូល ដែលប្រកបដោយធាតុ៤ ដី ទឹក ភ្លើង ខ្យល់ រូបអត់ចេះគិរពិចារណា អត់ដឹងសុខទុក្ខ អត់មានចលនាអ្វីទាំងអស់។ វេទនា អត់មានរូបទេ ជាចិត្តម្យ៉ាងសំរាប់ទទួលនាទី ដឹងសុខទុក្ខ មិនសុខទុក្ខ។ សញ្ញាអត់មានរូប ជាចិត្តសំរាប់ទទួលមុខនាទីដឹងតាមទ្វារ ភ្នែក ត្រចៀក ច្រមុះ អណ្តាត ។ល។ គឺ ឃើញ ធំក្លិន ដឹងរសជាតិ ដឹងប៉ះទង្គិចជាដើម។ ខន្ធ៥ បើគេបង្រួញអោយខ្លីមាន ២រូប ចាត់ជារូបដដែល វេទនា សញ្ញា សង្ខារ វិញ្ញាណ ចាត់ជានាម។ នាម មានតែឈ្មោះអត់រូបទេ តែជាធម្មជាតិ សំរាប់បង្អោនទៅរកអារម្មណ៍ គឺ ទទួលដឹងអារម្មណ៍ ឯរូបគ្មានដឹងអីទេ។ អ្វីដែលគេប្រកាន់មាំថា អត្តា... គឺ ខន្ធ៥ រូប និង នាម នេះឯង។



# អាឡាំង Alain (1868-1951)

លោក Alain មានឈ្មោះដើមថា Emile Chartier ជាអ្នកនិពន្ធ សៀវភៅទស្សនវិជ្ជា ល្បីៗមួយចំនួន មាន ចំណងជើងថា Propos sur bonheur[2] (គំនិត អំពី សុភមង្គល), des idées (គំនិត), des éléments de philosophie (វត្ថុធាតុ នៃ ទស្សនវិជ្ជា)។

## ១. គោលវិធី : លទ្ធភាព ទទួលបានគំនិត

ទស្សនវិទូ Alain គាត់មិន ក្រង នូវប្រព័ន្ធ, តែ ចង្អុលបង្ហាញ នូវគោលវិធីបញ្ញា : គឺថា ដាក់ នូវ សេចក្តីពិត និង អត្តភាព នៅក្នុង លំដាប់ថ្នាក់ នៃ ការពិចារណា និង ការត្រិះរិះ។ តើដូចម្តេចថា គិត ? បំពេញ នូវសកម្មភាព បញ្ញា ឬ វិចារណ: (rationnel), ថ្លឹងដោយប្រុងប្រយ័ត្ន នូវអ្វី ដែលចូលមកដល់វិញ្ញាណ (esprit), និយាយ ដោយមិនវិនិច្ឆ័យជាមុន លើអ្វីដែល គេវិនិច្ឆ័យពីមុនមកហើយ ដោយមិនយកវា មកសិក្សាសិន។ វិធីទស្សនវិជ្ជានេះ វាមានលក្ខណ: ទៅលើការបារម្ភ សំដៅទៅរក ការពិចារណាឈ្លាវៃ, តែក៏សំដៅ

[2] Propos sur le bonheur (1928), des idées (1932), des éléments de philosophie (1940) et d’autres œuvres.

ទៅរក សតិសម្បជញ្ញៈ (conscience), ទុកដូចជា ការចេះដឹង ដែលវា ត្រឡប់មកលើខ្លួនឯងវិញ និង ទំលាភាព នៃ Cogito[3]។ ដូចលោក Descartes ដែរ, លោក Alain គាត់ប្រកាសប្រដូច សតិសម្បជញ្ញៈ នឹង ចិត្តលក្ខណៈ (psychisme)។ រីឯ អសម្បជញ្ញៈ វិញ វាជារឿងប្រឌិត ឬ មិនពិត (mythe) - ប្រកបដោយគ្រោះថ្នាក់ កើតចេញពីទស្សនៈ Freudisme ដែលជាទស្សនៈ បង្ហាញថា នៅក្នុងចិត្តយើង មាន ហេតុការណ៏ជាច្រើន ឬ ការបង្ហាញ នៃចិត្តដែលខ្លួនឯង ក៏អត់ដឹងខ្លួនឯងបាន និង មិនអាចដឹងដោយវិញ្ញាណបាន - ដែលតម្រូវអោយយើង បន្ថយគិតពីរឿងប្រឌិតនេះ ហើយ យល់ឃើញថា វាគ្រាន់តែជា ចលនាសរសៃប្រសាទសាមញ្ញ, គឺថាជា វត្ថុសេរីរសាស្ត្រសុទ្ធសាធ។ម្យ៉ាងទៀត បំផ្លើស នូវពាក្យ អសម្បជញ្ញៈ តើមិនដូចជាប្រឆាំងនឹង គុណធម៌ (éthique) និង សើរើ នូវសេរីភាពដែលវាភ្ជាប់នឹង ឧបនិស្ស័យសីលធម៌ នៃយើង ?

---

[3] Cogito ទ្រឹស្តី របស់លោក Descartes ស្តីអំពី មនុស្សជាតិ ត្រូវតែមានអត្តភាពខ្លួនពិត ព្រោះ វាអាចសួរខ្លួនឯង នូវសំនួរបាន។

## ២. សីលធម៌

សួរថា តើអ្វី ដែលកំណត់ នូវសីលធម៌ ? សីលធម៌ ជាតំណាង ដោយសំណុំគោលការណ៍ លុះដល់ នូវការទទួលស្គាល់ នៃ វិញ្ញាណ និង នរសក្តិយស។ លោក Alain គាត់យល់ឃើញថា : គ្រប់សីលធម៌ មាននៅក្នុងការដឹងខ្លួនឯង ថាជាវិញ្ញាណ ហើយ នៅគំនិតនេះ គឺវា « តម្រូវអោយវិញ្ញាណ មាន កត ព្វកិច្ចពិតប្រាកដ »។ រស់នៅ តាម វិញ្ញាណ និង គុណធម៌ តើដូចម្តេច ? គឺ ការទទួលបាន នូវ សាកលភាព (Universalité) - នូវអ្វីដែលជាសិទ្ធិរួម នៅក្នុងវិញ្ញាណទាំង អស់ -, សាកលភាព មានលក្ខណៈ ជា ករណីណកិច្ច។ អោយ អត្ថន័យ តាមទ្រឹស្តី លោក Kant : ករណីយកិច្ច ដូចជា ចរិយា (conduite) នាំអោយយើងស្គាល់ នូវលក្ខណៈ នៃកត ព្វកិច្ច និង សាកលភាព : គ្រប់គ្នា ត្រូវធ្វើដូចគ្នា ដូចខ្ញុំធ្វើ និង ដូចដែលខ្ញុំបានធ្វើដោយខ្លួនឯង...។

នៅក្នុង លំហាត់សីលធម៌សកលនេះ វាភ្ជាប់ទៅនឹង ការត្រិះ រិះ និង ករណីយកិច្ច ដែលខ្ញុំ បានធ្វើការពិសោធជាជម្រៅ ទៅលើ សេរីភាព របស់ខ្ញុំ។ លោក Alain ដែលជាទស្សនវិទូ នៃសេរីភាព ប្រានចោល នូវព្រហ្មលិខិត (fatalisme) ដែល ជាទ្រឹស្តី ពន្យល់ថា គ្រប់អង្គហេតុទាំងឡាយ នៅលើលោក

នេះ វានៅក្រោមច្បាប់ ដោតវាសនា ដែលមិនអាចប្រកែកបាន។ គំនិត នៃអំណាចវាសនា ដែលជាអ្នកកំណត់ដាច់ខាត នូវចរន្ត នៃព្រឹត្តិការណ៍ មិនមែនជា គំនិតសីលធម៌នោះឡើយ។ ផ្ទុយពី ព្រហ្មលិខិត ខ្ចិលច្រអូស, បច្ច័យនិយម (déterminisme) - គំនិតលើ សំណុំ នៃមូលហេតុ ឬលក្ខខណ្ឌ កំណត់ នូវសំណុំ នៃអនុភាព (effet) - វាមិនត្រូវគ្នានឹង គុណធម៌ : ចំណេះដឹង នៃបច្ច័យនិយម អនុញ្ញាតអោយធ្វើសកម្មភាព ទៅលើវត្ថុទាំងឡាយ ; ដូច្នេះ វារួមចំណែកនូវការធ្វើលំហាត់ នៃសេរីភាព នៃយើង។ រស់នៅតាមវិញ្ញាណ គឺយកតាម នរសេរីភាព និង នរសក្តិយស។



# អារីស្តូត Aristote (384-322 av.J-c)

លោក Aristote ជាទស្សនវិទូ ជនជាតិក្រិច ដែលជាអតីតសិស្សលោក Platon ដែកក្លាយទៅជា សាវ័កស្មោះត្រង់ តែគាត់បានរិះគន់ទៅលើប្រធានបទខ្លះ ដូចយ៉ាង ទ្រឹស្តី នៃគំនិត។

យើងលើកយកមកនិយាយអំពីគំនិតសំខាន់ពីរ គឺ : រូប (physique) និង បរមត្ថវិជ្ជា (métaphysique) ឬ នាមរូបវិជ្ជា។ ពាក្យ métaphysique មិនមែនលោក Aristote ជាអ្នកបង្កើត នោះទេ, គឺ លោក Andronicos de Rhodes នៅសតវត្សទី១ បានយកពាក្យនេះ មកដាក់ឈ្មោះ នូវស្នាដៃ របស់លោក Aristote។

Aristote ជាអ្នកស្រាវជ្រាវធំ និង សាស្តាម្នាក់ ដែល បានរៀបចំជាប្រព័ន្ធ នូវគ្រប់ចំណេះដឹង នៅក្នុងសម័យរបស់គាត់។ គំនិតប្រជុំវិជ្ជានេះ បានបង្កើត នូវទម្រង់ នៃក្របខណ្ឌ តក្កវិជ្ជា, ទ្រឹស្តី, នយោបាយ។ ចំណេះដឹង ទាំងឡាយនេះ ជាក្របខណ្ឌ នៃចំណេះដឹង នៃយើងសព្វថ្ងៃនេះ។ ជាចំបង គឺគាត់ជា អ្នកបង្កើត តក្កវិជ្ជា ឬ វិជ្ជាត្រិះរិះ គឺចំណេះខាងពិចារណារកហេតុផល។

## ១. តក្កវិជ្ជា

ពាក្យ Logique នេះ លោក Aristote គាត់មិនធ្លាប់យកមកប្រើទេ, តែយ៉ាងណាមិញ គាត់ជាអ្នកបង្កើតទីមួយ នូវទ្រឹស្តី តក្កវិជ្ជា ជាប្រព័ន្ធ, គឺជា វិន័យ កំណត់ នូវដំណើរ នៃគំនិត ដែលអាចចាត់ទុកបានថា វាមានសុពលភាព ឬ វាគ្មានសុពលភាព។ ការសិក្សានេះ ធ្វើឡើង យោងតាមទស្សនៈជាក់លាក់ គឺថា ដោយឯករាជ្យពីអត្ថរវត្ថុ។ ការសិក្សានេះ ត្រូវគេប្រមូលមកក្រងផ្តុំគ្នានៅសតវត្សទី២ ដាក់ឈ្មោះថា Organon[4] គឺមានន័យថា គ្រឿង (instrument) នៃគំនិត។ នៅក្នុងស្នាដៃនេះ លោក Aristote ផ្ចិតផ្ចង់ ទៅលើ ការពន្យល់បែប Syllogisme[5] គឺថា ផ្តើមដំបូង ពីការសន្និដ្ឋាន នៃសេចក្តីពិត ហើយយកវាមកបន្ត តាមរបៀបវិទ្យាសាស្ត្រ និង ម៉ត់ចត់។ តើពាក្យ Syllogisme ចង្អុលបង្ហាញន័យអ្វី ? គឺជា សុន្ទរកថា ស្តីអំពី វត្ថុខ្លះ ដែលយកវាមកសួរ ដើម្បីបង្ហាញ នូវសេចក្តីពិតមួយ ហើយ វត្ថុផ្សេងទៀត វាអាស្រ័យទៅលើសេចក្តីពិតនោះ ជាចាំបាច់ : គ្រប់

---

[4] Organon គេទុកជាគោលការណ៍មជ្ឈឹម នៃទស្សនវិជ្ជា របស់លោក Aristote។

[5] ការពិចារណាជាទំរង់ ពី ប្រយោគ (proposition) ពីរ ហើយធ្វើសេចក្តីសន្និដ្ឋានថាពិត : គ្រប់មនុស្សលុះក្នុងសេចក្តីស្លាប់, លោក Socrate ជាមនុស្ស ដូច្នេះ គាត់លុះក្នុងសេចក្តីស្លាប់។

មនុស្ស លុះក្នុងសេចក្តីស្លាប់, លោក Socrate ជាមនុស្ស ដូច្នេះ គាត់លុះក្នុងសេចក្តីស្លាប់។ ជាអាទិ៍ តក្កវិជ្ជា របស់ លោក Aristote ជាការសិក្សា នៃ Syllogisme, តែ គាត់ បានសិក្សាដែរអំពី ប្រយោគ, ការសំដែងគំនិត នៃការវិនិច្ឆ័យ នៅក្នុងពាក្យ, គាត់ ចាត់ថ្នាក់ នូវការវិនិច្ឆ័យ ហើយ កំណត់អោយទៅជា វិទ្យាសាស្ត្រ - ដូចជា ប្រព័ន្ធ នៅក្នុងនោះ របស់អ្វីដែលស្គាល់ គឺមានមកអំពី របៀបចាំបាច់ នៃប្រព័ន្ធនោះ ដែលទុកជាគោលការណ៍ដើម។ វិទ្យាសាស្ត្រ ជា ប្រភេទមួយ នៃចំណេះដឹងសាកល, សកល តាមលោក Aristote គឺវាត្រួតលើគ្រប់ករណី។ ដើម្បី លុះដល់ វិទ្យាសាស្ត្រ គឺមិនត្រូវធ្វេសនឹង induction[6] (វិសេសានុមាន) ដែលវាស្ថិតនៅលើ ការនាំផ្លូវពី ករណីពិសេស ទៅរក ករណីសាកល។

នៅទីបញ្ចប់ លោក Aristote ប្រកាសអំពី គោលការណ៍ នៃអបដិវាទកម្ម (non-contradiction) - តាមគោលការណ៍នេះ វាមិនអាចមានបាន នូវរបស់កំណត់អោយដូចគ្នា

[6] ការពិចារណា ឋិតនៅលើ ធ្វើការប្រមូល នូវ ឈុត នៃការសង្កេត ពិសេស ដើម្បី បង្កើត នូវសេចក្តីសន្និដ្ឋានទូទៅ។

(même attribut) ជាកម្មសិទ្ធ ឬមិនមែនជាកម្មសិទ្ធ របស់ប្រធាន (sujet) មួយ ក្នុងពេលជាមួយគ្នា និង នៅក្រោមការទាក់ទងដូចគ្នា - ដែលគ្មានទាក់ទងទៅនឹងប្រធានទី៣ ច្រានចោល - តាមទំនាក់ទំនង នៃប្រយោគពីរ ផ្ទុយគ្នា, មួយជាសេចក្តីពិត ហើយមួយទៀត ជាសេចក្តីមិនពិត។

## ២. រូប

### ក. ដើមហេតុ និង ចៃដន្យ

រូប គឺ សិក្សាអំពី « Phusis » ប្រែថា ធម្មជាតិ, និង ប្រមើលគិតអំពី សេចក្តីពិត ដែលមិនអាចប្រែប្រួលបាន (តាមការប្រឆាំងនឹងបរមត្ថវិជ្ជា ដែលជាវត្ថុនឹងនរ និង គ្មានទីបញ្ចប់)។ ការសិក្សា ពិសេសអំពី មូលហេតុ នៃការប្រែប្រួលនៅក្នុងធម្មជាតិ, មូលហេតុនេះ ដែលត្រូវបានកំណត់ ដូចជាត្រូវឆ្លើយនឹងសំនួរថា « ហេតុអ្វី ? » ។ វាមាន ដើមហេតុ៤យ៉ាង ដែលអាចនាំអោយស្គាល់ និង យល់ អំពី ការបង្កើត នៃសេចក្តីពិត : ដើមហេតុសម្ភារៈ - ដែលវត្ថុបានកើតឡើង -, ដើមហេតុជាក់លាក់ - គឺថា គំរូ និង ទំរង់ដែលមានឡើងដោយខ្លួនឯង -, ដើមហេតុបង្កើតផល - គឺថា ចលករ និង ភ្នាក់ងារ -, ដើមហេតុចុងក្រោយ - គឺថាមូលហេតុ ឬ ទីបញ្ចប់។ លើក ឧទាហរណ៍មួយ ដើម្បីស្រួល

យល់ អំពី ដើមហេតុទាំង៤នេះ (ជាងចម្លាក់ និង រូបចម្លាក់) : ថ្មកែ ជាដើមហេតុសម្ភារៈ, គំនិត និង ទ្រង់ទ្រាយនៃស្នាដៃ របស់ជាងចម្លាក់ ជាដើមហេតុជាក់លាក់, ការវាយឧបករណ៍ធ្លាក់ទៅលើថ្មកែវ ជាដើមហេតុបង្កើយផល ហើយនៅទីបញ្ចប់ ចំណង់ ចង់បានប្រាក់ ឬ កិត្តិគុណ ជាដើមហេតុចុងក្រោយ។ ដើមហេតុសម្ភារៈ មានសារៈសំខាន់ពិសេស នៅពេល ដែលដើមហេតុនេះ រចនា រូបធាតុ (matière) - គឺថា ឫទ្ធានុភាព និង សក្តានុពលភាព ដែលមិនទាន់ចប់សព្វគ្រប់ - បង្កើតផ្លូវឆ្លង នូវឫទ្ធានុភាព នៃកិច្ច ដែល វាជាអទត្តពល[7] (virtuel) ឬ និម្មិត ទៅរក សមិទ្ធិកម្ម។ តើអ្វីជាទម្រង់ ? ចំពោះលោក Aristote គឺជាគោលការណ៍ កំណត់ នូវរូបធាតុ ហើយ ដែលវានាំមក នូវអត្ថរស់សំរេចបានច្បាស់លាស់។

## ខ. ការពន្យល់អំពី ជីវន្តភាព (Explication du vivant)

ជាសេចក្តីពន្យល់ បែប ជីវិតន្រ្ទីយនិយម[8] ហើយមិនមែននៅលើចំណុច យុន្តកម្ម។ ជាគោលការណ៍ សំរាប់ជីវិត និង

[7] ដែលអាចកើតមានទៅខាងមុខ។
[8] លទ្ធិខាងជីវសាស្រ្ត ដែលនិយាយថា មានជីវិតមួយដោយលែកអំពីព្រលឹង និង សារពាង្គកាយ។

ព្រលឹង ដែលផ្តល់ នូវចំណុចសំខាន់ នៃការពន្យល់។ តែត្រូវយល់ដែរអំពីខ្លឹមសារ នៃពាក្យព្រលឹង : ព្រលឹង គឺជានាមរូប នៃសារពាង្គកាយ មានការរៀបចំត្រឹមត្រូវ, ជាកម្លាំងសំរាប់ធ្វើជីវចល នូវសព៌ាង្គកាយ។ ឬ វាអាចកំណត់ នូវភាពឯករាជ្យរបស់ខ្លួន ចំពោះសារពាង្គកាយ។ ព្រលឹង វាភ្ជាប់នឹងសារពាង្គកាយ និង ជីវិត, គឺថា វាចិញ្ចឹមខ្លួន, បង្កើនខ្លួន និង ខ្លួនចុះដុនដាប ដោយខ្លួនឯង។

## ៣. បរមត្ថវិជ្ជា ឬ នាមរូបវិជ្ជា

មែនទែន គឺអ្វីដែលកើតឡើង បន្ទាប់ពីរូប, ជាការសិក្សាតួអង្គមនុស្ស ថាខ្លួនជាមនុស្ស, គឺថា សេចក្តីពិត ជាគោលនៃ ទម្រង់បរិសុទ្ធ, សារធាតុ រស់នៅ បន្ទាប់ពីមានការផ្លាស់ប្តូរ កើតពីគ្រោះថ្នាក់អ្វីមួយ។ វត្ថុធាតុចុងក្រោយ នៃបរមត្ថវិជ្ជា គឺ អាទិទេព ដែលជា កិច្ចបរិសុទ្ធ (acte pur) ដែលជាកិច្ច ធ្វើចរន្តកម្ម និង សម្រេចសព្វគ្រប់ នូវគ្រប់សុក្រឹតភាព។ ធ្វើអោយវិសេសវិសាល នៃលោកិយ, អាទិទេពផ្លាស់ប្តូរ វត្ថុអ្វីមួយ តែខ្លួនវិញឋិតនៅដដែល : ដូច្នេះ អាទិទេព ជាចលករដើម ហើយ ជាតំណាង នៃដើមហេតុ នូវគ្រប់បំលាស់ប្តូរ នៅក្នុងលោកិយ ដែលយើងអាចទុកជាជីវិនអនន្ត (un vivant éternel)។

## ៤. សីលធម៌ និង នយោបាយ

ទស្សនៈសីលធម៌ របស់លោក Aristote គឺឋិត ក្នុងស្នាដៃនិព័ន្ធពិសេស របស់គាត់ ឈ្មោះថា éthique à Nicomaque (គុណធម៌ នៅ ណីកូមាគ) ជាស្នាដៃសំខាន់ និយាយអំពី បុរមសុខ (eudémoniste) ដូចជាទស្សនវិជ្ជាដទៃទៀត អំពីសីលធម៌ នៅសម័យបូរាណ។ ជាទស្សនៈ ទុក សុភមង្គល ជាគោលដៅចុងក្រោយ របស់មនុស្ស។ តែសួរថា តើ សុភមង្គល វាកំណត់អ្វី ? ខ្លឹមសារវា គឺជាសកម្មភាព នៃវិចារណញ្ញាណ (raison), ជាសកម្មភាពឋិតនៅលើ ការសញ្ជឹងគិត : ជីវិតសញ្ជឹងគិត ជាធម្មតា វាទាក់ទងនឹងធាតុអាទិទេព ដែលមាន នៅក្នុងវិចារណញ្ញាណ របស់មនុស្ស និង អនុញ្ញាត អោយមនុស្សយល់អំពី កុសលធិបតេយ្យ (Souverain Bien) នៃខ្លួន, គឺថា កុសល វិសេសវិសាល ដែលជា សេចក្តីល្អតែមួយគត់ សំរាប់ខ្លួនឯង។

នៅក្នុងការវិភាគ អំពីសុភមង្គលនេះ, លោក Aristote មិនពាយងាយ អំពី ការសប្បាយ : ការសប្បាយ គឺជាការបង្ហើយនៃកិច្ច, គឺវាបន្ថែម បង្កើនទៅលើកិច្ច ដូចជា បង្កើនន្ទូវភាពឆើតនៅពេលជរាភាព។

ពិតហើយថា ការវិភាពអំពី សីលធម៌ វាមិនចែកដាច់ពីការវិភាគអំពី នយោបាយ។ ក៏ដូច អ្នកប្រាជ្ញផ្សេងៗ ផ្នែកគំនិតធំៗ ដទៃទៀតដែរ, លោក Aristote បានប្រមូលសីលធម៌អោយមានតែមួយ គឺសិក្សាអំពី កុសល និង សេចក្តីល្អ (Bien et Bon) និង នយោបាយ គឺសិក្សាអំពី វិទ្យា នៃបុរី។ តើនឹងអាចចែកចេញពីគ្នាដូចម្តេចបាន សីលធម៌ និង នយោបាយ, ខណៈដែលគេទុកមនុស្ស ជាសត្វនយោបាយដ៏សំខាន់ រស់នៅក្នុងបុរី ? វិភាគលើ ការរៀបចំបុរី, លោក Aristote បែងចែក នូវទម្រង់ផ្សេងៗ នៃការដឹកនាំហើយ បង្ហាញ នូវទម្រង់សំខាន់បីយ៉ាង : រាជានិយម, រដ្ឋ ដឹកនាំដោយ មនុស្សតែម្នាក់គត់ ដើម្បីស្វែងរកប្រយោជន៍រួម, រដ្ឋ ដឹកនាំដោយ វណ្ណអភិជន និង  សាធារណរដ្ឋ ដឹកនាំដោយមនុស្សមួយក្រុម ដើម្បីអាណាប្រយោជន៏។ រាជានិយម អាចប្រែក្លាយជារបបប្រជាហិង្សា, អភិជនាធិបតេយ្យ អាចប្រែក្លាយជាអប្បជនាធិបតេយ្យ (oligarchie), សាធារណរដ្ឋអាចប្រែក្លាយជា លទ្ធិប្រជាធិបតេយ្យ។

ទស្សនវិជ្ជា នៃតក្កវិជ្ជា របស់លោក Aristote ផ្តល់ នូវចក្ខុវិស័យ នៃរចនសម្ព័ន្ធ ដែលបង្ហាញអោយយើងដឹង នូវអត្តភាព នៃតួអង្គមនុស្ស។ លោក Aristote មិនយក រូបភាព

នៃគតិបណ្ឌិត មកភ្ជាប់នៅក្នុងការសិក្សា របស់គាត់នោះឡើយ ៖ គាត់ចាត់ទុកជាស្រេចថា ជនណាដែលមានតំរិះផ្សេងៗ ជា ជន មាន ឧត្តមគតិដ៏ល្អប្រសើរ។ ទស្សនៈនេះដែលយើងយកមកសិក្សា និង ពិចារណារហូតមកដល់សព្វថ្ងៃនេះ។



## ប៊ែសុន Bergson (1859-1941)

លោក Henry Bergson ជាទស្សនវិទូ ជនជាតិបារាំង។ ស្នាដៃនិពន្ធសំខាន់ របស់លោកគឺ ការសាកល្បង ពិចារណា អំពី ទិន្នន័យភ្លាមៗ នៃសតិសម្បជញ្ញៈ (១៨៨៩), រូបធាតុ និង សតិ (១៨៩៦), សំណើច (១៩០០), ការវិវត្តិបង្កើត (១៩០៧), ឋាមពល អភិញ្ញាចិត្ត (១៩១៩), ប្រភពពីរ នៃសីលធម៌ និង សាសនា (១៩៣២) និង ការត្រិះរិះ និង ការមិនឋិតថេរ (១៩៣៤)[9]។ លោកជំទាស់នឹងទ្រឹស្ដី បតិដ្ឋាននិយមសម្ភារៈ (positivisme matérialiste) ដែលនាំអោយគាត់ វិលត្រឡប់មករកការពិចារណាលើ ទិន្នន័យភ្លាមៗ នៃសតិសម្បជញ្ញៈ តែនៅក្នុងតែ « រយៈពេល » និង « គុណភាពបរិសុទ្ធ »។

### ១. អព្ភន្តរញ្ញាណ[10] ឬ ប្រាជ្ញាខាងក្នុង

នៅសតវត្សទី១៩ និង ពាក់កណ្ដាល នៃសតវត្សទី២០ ឥទ្ធិពលលោក Bergson មានក្រៃលែង ដោយសារគាត់ សើរើ

---

[9] L’Essai sur les données immédiates de la conscience (1889), Matière et mémoire (1896), Le Rire (1900), L’évolution créative (1907), l’Energie spirituelle (1919), les deux Sources de la morale et de la religion (1932) et la Pensée et le Mouvant (1934).

[10] ការយល់ដឹងច្បាស់ ដោយមិនចាំបាច់ពិចារណា។ អព្ភន្តរ (បា., សំ. អភ្យន្តរ ឬ អភ្យាន្តរ) ខាងក្នុង, ប៉ែកខាងក្នុង។ ញ្ញាណ ឬ ញាណ គឺសេចក្ដីដឹងច្បាស់, ប្រាជ្ញា។

នូវទស្សវិជ្ជាបញ្ញា - ដែលទាមទារថា អាចនាំទៅដល់ សេចក្ដីពិត តាម ការលំហាត់ នៃបញ្ញា - និង ដំណោះស្រាយ « វិទ្យានិយម » (Scientistes), ដោយយល់ឃើញថាមានតែវិជ្ជាវិទ្យាសាស្ត្រមួយគត់ ដែលអាចរក នូវដំណោះស្រាយបាន។ ប៉ុន្តែសួរថា តើ បញ្ញា វាអាចអោយយើង ស្រវ៉ាចាប់ នូវសេចក្ដីពិត ដូចម្ដេចបាន ? គឺនៅក្នុង ពុម្ព នៃសកម្មភាព ដែលខ្លួនយកទម្រង់តាម។ បញ្ញា មិនកំណត់តាំងពីលំដាប់ដំបូងមក នូវ ញាតិសតិ ( une faculté ) ប៉ាន់ស្មានបរិសុទ្ធ តែប៉ុណ្ណោះទេ, គឺវា កំណត់ដែរ នូវអំណាចសកម្ម របស់ខ្លួនដែរ។ ប្រមើលថា អ្វីដែលហាក់បីដូចជាដំណើរដំបូង គឺវាឋិតនៅលើ បដិសន្ធិ នៃវត្ថុធាតុ សិប្បនិមិត្ត និង ធ្វើអោយប្រែប្រួល នៃដំណើរ នៃការផលិត។ - មនុស្ស អ្នកនិមិត្ត (Homo faber) - គឺជាមនុស្សមុនដំបូងមុនទៅជា មនុស្ស អ្នកមានប្រាជ្ញា (homo sapiens) - មនុស្ស គតិបណ្ឌិត (homme sage) -, មនុស្សលោកនេះ ជាដំបូង គឺ សម្ភារ គ្រប់គ្រងលើធម្មជាតិ និង យកវាមកប្រើទៅតាមការចង់បាន របស់ខ្លួន។ បញ្ញា អនុញ្ញាត ដែរ អោយគ្រោងទុកជាមុន និង រៀបចំអោយមានប្រយោជន៍ដល់សកម្មភាព។ តែនៅ ពេលដែល ទស្សនវិទូ ស្នើរ រុករាន

ចូលទៅក្នុង ឯករាជ្យភាពដាច់ខាត (l’Absolu)[11] (អ្វីមួយដែលមិនអាស្រ័យទៅលើអ្វីសោះ ឬ សេចក្តីពិតដាច់ខាតគ្មានប្រែប្រួល) - អ្វីដែលវាល្អឥតខ្ចោះ នៅក្នុងនោះ វាជាអ្វីដែលឥតខ្ចោះរួចស្រេច ហើយវាមិនអាស្រ័យទៅលើនិមិត្តសញ្ញាមិនទៀងណាមួយ - តើវាមិនត្រូវ ដើរតាមវិថីផ្សេងមួយទៀត និង ប៉ុនប៉ង សំងំគិត (s’abstraire) នូវគោលវិធី និង វិធីសាស្ត្រ - ឧបមា ការវិភាគ ទៅលើ ការធ្វើអោយ វត្ថុមួយ ទៅជាវត្ថុធាតុទាំងឡាយ ដែលគេធ្លាប់ស្គាល់រួចហើយ និង រៀបរៀងវាឡើងវិញ...។ល។ - វាសម្រប ជាសារវន្តទៅនឹង ពុម្ភ នៃសកម្មភាព ? វិទ្យាសាស្ត្រ វាផ្អែកទៅលើបញ្ញា និង អនុវត្តទៅលើវត្ថុធាតុ នៃវិធីគណនា និង ការរាស់។ ធ្វើបែបនេះ វាបង្កើត នូវរូបភាពមានប្រយោជន៍ ហើយបន្តរហូតដល់ទៅរបៀបធ្វើ, តែវាមិនជ្រលួសពីដែននៃ ការមិនទៀង (Relatif) បានឡើយ។ វាបង្កើត នូវច្បាប់វិទ្យាសាស្ត្រទាំងឡាយ, គឺថា វាមានការទាក់ទងខ្ជាប់ខ្ជួនរវាង ភាពអស្ចារ្យ គ្នា ដែលវាប្រែប្រួល តែវាមិន រុករានចូល

[11] ឯករាជ្យភាព (Absolu) ផ្ទុយនឹង វិក្រាយភាព (Relatif) : ពាក្យឯករាជ្យភាពប្រើនោក្នុងន័យទស្សនវិជ្ជា។

ទៅក្នុង ឯករាជ្យភាពដាច់ខាត។ តើតាមផ្លូវណា ដែលសង្ឃឹមថាមាន ការ រុករានចូលក្នុង ឯករាជ្យភាពដាច់ខាត ? យើងត្រូវតែ បដិសេធ មិនត្រឹមតែ បញ្ញា គឺត្រូវបដិសេធ នូវភាសា ដែលវាមានការជាប់ទាក់ទងគ្នាជិតស្និទ្ធ : គ្រឿង នៃបញ្ញា, ភាសា វាតំណាងរូម នូវសញ្ញាសម្គាល់នូវពាក្យសំដី ដែលកត់សំគាល់ នូវវត្ថុទាំងឡាយ តែទិដ្ឋភាពទូទៅ និង សាមញ្ញបំផុត ដែលជាសញ្ញា បញ្ជាក់និង ធ្វើអោយនឹងគាំងណែន នូវវត្ថុដែលអាចប្ដូរ និង ប្រែប្រួលបាន។ សញ្ញានៃភាសា វាគ្រាន់តែជា ស្លាកបិទនៅលើវត្ថុ។ ពាក្យ កំណត់ នូវប្រភេទ, គំនិតទូទៅ ទាក់ទងទៅនឹងក្រុមមួយ នៃភាវៈទាំងឡាយ ដែលមាន នូវលក្ខណៈដូចគ្នា។ វាមិនអាចសំដែងបាន នូវសេចក្ដីពិត ជាគោលដៅ និងលក្ខណៈចិត្ត នៃយើង : ដូច បញ្ញា ដែរ គឺជា គ្រឿង នៃសកម្មភាព។ នៅពេលដែល ផ្លូវ នៃភាពភ្លាម គ្មានមានបុព្វសិទ្ធ ទៅលើ ទស្សនៈ នៃវាចារ និង បញ្ញាជាវិចារ (intelligence discursive) ? តាម វិធី នៃចំណេះដឹងភ្លាមផ្ទាល់, តាម សាមានចិត្ត ដែលធ្វើអោយយើង ជាប់គ្នាជាមួយនឹងវត្ថុ ដែលមាន តែមួយ និង មិនអាចសំដែងបាន, អធិប្បាយថា តាម អព្ភន្តរញ្ញាណ (intuition) យើងរុករានទៅក្នុង ភាវៈជ្រៅ នៃសេចក្ដីពិត : អព្ភន្តរញ្ញាណ

បង្ហាញ នូវការវិលត្រឡប់មករកខ្លួនឯងវិញ និង ទៅរកភារៈយើងពិតប្រាកដ, ការវិលត្រឡប់ធ្វើឡើង ដោយគ្មានអន្តរការ។

## ២. ជីវិតក្នុង : រយៈពេល, សេរីភាព, សតិ

គឺជីវិតក្នុងនេះឯង ដែលអព្ភន្តរញ្ញាណ ជាដំបូង អនុញ្ញាតអោយយើងរកឃើញ។ ហើយ, ជាជម្មតា, ចំណេះដឹងយល់ច្បាស់ខ្លួនឯង (connaissance intuitive) នាំអោយរកឃើញវិញ នូវរយៈពេល បរិសុទ្ធ, ជារូបភាព នៃភារៈ នៃសតិសម្បជញ្ញៈ នៃយើង នៅពេល ដែល អាត្ម (moi) នៃយើង ទុកអោយវារស់នៅ, នៅពេល ដែលវា តម្អឹង (s'abstient) បង្កើតនូវការបំបែក រវាង ភារៈកាលឥឡូវ និង បុរេភារៈទាំងឡាយ។ លំហូរដោយរលូន, វិសភាគភាព (hétérogénéité) បរិសុទ្ធ, អភិគមគុណលក្ខណៈ, រយៈពេល វាដូចជា និស្ស័យនៃអាត្មយើង។ ប៉ុន្តែ ការលុះភាព និរន្តរ៍, សុវចៈ (souple), គុណលក្ខណៈ, នោះឯង វាបង្ហាញយើង នូវវិចយកិរិយាខាងក្នុង[12] ផ្អែកទៅលើ អព្ភន្តរញ្ញាណ។

[12] Investigation métaphysique.

តែថា អ្វីដែលក្លាយជា គុណលក្ខណៈ (Qualitatif) នេះ វាតែងតែមិនអាចគ្រងទុកជាមុនបាន។ ដ្បិត អាត្មជ្រៅ (ជាសារវន្ត), គឺអ្វីដែលបង្ហាញដល់យើង នូវ « ទិន្នន័យ ភ្លាម» នៃ សតិសម្បជញ្ញៈ គឺជា សេរីភាព។ បើសិនជា អាត្មារាក់ - ចំណែក នៃលក្ខណៈចិត្ត នៃយើង វាសូន ទៅតាម ការសន្ទត និង ទៅតាម សង្គម - វានាំមក ជាញឹកញាយ នូវការបន្ត នៃលក្ខណៈស្វ័យប្រវត្តិ, ជីវិតផ្ទៃក្នុងពិតប្រាកដ នៃយើង, រយៈពេល នៃយើង វានៅក្នុងជម្រៅ នៃសេរីភាព។ តើនៅពេលណា ដែលយើង ជាជនសេរី? នៅពេលដែលយើង ទៅហួសពី សំបករាក់ (croûte superficielle) នៃសញ្ញា ភាសា, ពីពាក្យ, ពីសង្គម, នៅពេលដែល អំពើ វាចេញអំពី អត្តៈ (personnalité) នៃយើង ទាំងមូល ហើយ វាសំដែងចេញឡើង។ សេរីភាព វាសំដែងដោយខ្លួនឯង នៅពេលវាផ្សព្វនឹង អាត្មជ្រៅ នៃយើង តាម សមគ្គ (ការព្រមព្រៀងគ្នា) ពិត ជាមួយអាត្ម។ គឺនៅពេលនោះឯង ដែលអាត្មជ្រៅ វាលេចចេញមកដល់ផ្ទៃក្រៅ។ ដូច្នេះ សេរីភាព វាជា ការបំភល តែមួយ ជាមួយគ្នានឹង អាត្មជ្រៅ។

នៅទីបញ្ចប់, ជីវិតផ្ទៃក្នុង នៃយើង គឺសតិ (mémoire)។ នៅទីនេះ យើងលើកយក សតិធំពីរយ៉ាង មកអធិប្បាយ :

សតិ-ធម្មតា ដែលវាមាន ជាលក្ខណៈស្វ័យប្រវត្តិ និង ជាយន្តកម្ម ចលករ : នៅពេលដែលខ្ញុំសិក្សាអត្ថបទរត់មាត់ គឺខ្ញុំបានអនុវត្ត និង បន្ទួន នូវកាយវិការមួយចំនួន ដែលខ្ញុំធ្លាប់ស្គាល់ ; សតិ-ធម្មតា បង្ហាញ នូវសារៈយន្តកម្មសារីរិក ជាការពិត។ ផ្ទុយនឹង លក្ខណៈស្វ័យប្រវត្ត, សតិបរិសុទ្ធ គឺវាជាប្រវត្តិ នៃអាត្ម : អ្វីដែលកើតឡើងពីអតីតកាល បន្តរស់នៅក្នុងអាត្ម ជារូបភាព នៃអនុស្សាវរីយ៍បរិសុទ្ធ, ដែលមិនអាចរលាយបាន, ដែលឯករាជ ចំពោះសារពាង្គកាយ។ សតិ បរិសុទ្ធ ផ្ទុក នូវអតីតកាល នៃយើង និង វាជា សារៈជាចិត្ត (essence spirituelle) ពិតប្រាកដ។

### ៣. ជីវជវនៈ (élan vital)

អព្ភន្តរញ្ញាណ (ការយល់ច្បាស់ដោយមិនបាច់ពិចារណា) វាមិនត្រឹមតែបើក នូវថាមភាពចិត្ត នៃយើង តែវាបើកដែរនូវ រយៈពេល នៃសាកលលោក និង ខ្យល់ធំ នៃជីវិត។ ក៏ដូចជា ការពិសោធផ្ទៃក្នុង នៃយើង ដែលមានមកពីរយៈពេល និង ការប្រែប្រួលគុណលក្ខណៈ, ក៏ដូច វាត្បាញ ខ្សែដែល វារីកធំ ដោយខ្លួនឯង មិនចេះចប់, ក៏ដូច ការពិត វាក្លាយខ្លួនវាជាការពិត និង ការវិវត្តន៍ ជានិច្ច។ តែសួរថាតើត្រូវគិតដូចម្តេច ដើម្បីយល់អំពី ការវិវត្តន៍នេះ ? លោក

Bergson បដិសេធ នូវទ្រឹស្តី និង ឧបធារណ៍ (ការសន្មត់) នៃយន្តកម្ម (postulats mécanistes) ទាំងឡាយ របស់ លោក Darwin និង អវសាននិយម (finalisme)។ ក្នុងករណីទី១ (យន្តកម្ម), ការពន្យល់ បែប រូបសាស្ត្រ-គីមី វាសន្មត់ថា គ្រប់គ្រាន់ហើយ, តែថា  យន្តកម្ម វាខ្វាក់ចំពោះ ដំណុះ នៃ ជីវន្តភាព នៅក្នុង ពេលវេលា និង ថាមភាព។ ជាមួយនឹង យន្តកម្ម, វាផ្តល់អោយគ្រប់បែបយ៉ាង ហើយវាយក ជវនៈ នៃជីវិត ទៅដាក់ទុក នៅក្នុង វង់ក្រចក។ តែ ទ្រឹស្តី អវសាននិយម - ដែលបញ្ជូនត្រឡប់មកវិញ នូវចេតនា និង គម្រោងការ ដែល ធ្វើចរន្តការ ដោយខ្លួនឯង នៅ ក្នុងជីវិត - ហើយ វាយក ពេលវេលា និង អ្វីមួយដែលនឹង ក្លាយជា បិកា (créateur) ទៅដាក់ទុកដែរ នៅក្នុង វង់ក្រចក : ទ្រឹស្តី អវសាននិយម ធ្វើដូចជា គ្រប់អ្វីៗ វាមាន តាំងពីមុនមកម្លេះ, សូម្បីខ្លួនឯងក៏វាដូច្នេះដែរ។ ចេតនា បរិសង្ខារ[13] (préformé) នេះ វានឹងអាចពន្យល់បានគ្រប់ បែបយ៉ាង។

[13] សង្ខារ ប្រែថា ផ្សំគ្នា ប៉ុន្តែតាមទម្លាប់ គេប្រែថា ប្រជុំតាក់តែង។

ដោយហេតុថា គ្រប់អ្វីដែលមានជីវិត (espèces vivants) ញែកឃ្លាតពីគ្នា ពីគំនិត នៃជីវនៈដើម ដែលវាផ្តល់អោយយើង។ ជីវជវនៈ កំណត់ នូវអភិក្រម នៃបិកាមិនអាចស្ថានបាន នៃ ចរន្តមួយ រត់តាមរយៈសារពាង្គកាយ ដែលជីវជវនៈ ជាអ្នករៀបចំឡើង។ ដូច្នេះ ពលវេគដើម (impulsion originelle) នៃការបង្កើតនេះ វាប្រឌិត នូវសណ្ឋានទាំងឡាយ ដែលកាន់តែមានរូបរាងស្មុកស្មាញឡើងៗ។ ដើម្បីយល់អំពី អត្ថរស់ នៃ ជីវជវនៈនេះ, យើងគិតភ្នក អំពី រយៈពេលបរិសុទ្ធ ដែលជា ការកើតឡើងដោយខ្លួនឯង។ ជីវនៈ វាជា ភាវៈខ្លួនឯង ហើយខ្លួនឯង ជា ការប្រឌិត : វាធ្វើសមិទ្ធិកម្ម នៃសភាវគតិថ្មីទាំងឡាយ និង សរីរាង្គ ដែលវាគ្មាន, បង្កើតដោយសារ សយម្ភូតភាព (spontanéité), រូបរាងស្មុកស្មាញ ហើយមិនបានរំពឹងទុកផង ដែលជា ការផ្សំជម្មតា នៃយន្តកម្ម មិនអាចនឹងពន្យល់វាបាន។

ដូច្នេះ ការវិភាគទាំងឡាយ របស់លោក Bergson នាំបង្ហាញថា ជីវិត ជា ដំណើរបិកា និង ការប្រឹងប្រែង ដើម្បីឡើង ទំនាល ក៏ដូចគ្នានឹងចុះដែរ។

## ៤. សីលធម៌, សាសនា, សិល្បៈ

ដូចគ្នានឹង ទស្សនវិស័យ ថាមវន្ត វាបំភ្លឺ នូវបាតុភូតសីលធម៌, សាសនា និង សិល្បៈ។ ទីនេះ, ប្រែ ពាក្យខ្លីមថា « បើកទ្វារ » : តែបើកអោយទាំងអស់គ្នា រត់ចេញពី វង់ នៃក្បួនខ្នាតបន្ទប់ និង តឹងរ៉ឹង ហើយ វាបើកទ្វារដោយខ្លួនឯងដល់ ជីវនៈ នៃជីវិត និង ការបង្កើត។ ដូច្នេះ នៅក្នុងសីលធម៌បើកទ្វារ ជាស្នាដៃ នៃជីវនៈចិត្ត (élan spirituel)។ ចំណែក សីលធម៌បិទទ្វារ វិញ វាកំណត់ តែសរព័នជាប់គាំ នៃបញ្ញត្តិ ជាលក្ខណៈចាំបាច់, ដែលជាផលសាមញ្ញ សំរាប់រៀបចំសង្គម, សីលធម៌បើកទ្វារថាមវន្ត : សំដែង មិនតែលើចំណុច នៃប្រព័ន្ធជាប់គាំង ដែលជាកតព្វកិច្ចសង្គម, តែលើ ការបង្កើត នៃសីលធម៌, ការអំពាវនាវ ជាប់នឹង ថាមពលចិត្ត។ ដូចយ៉ាង សីលធម៌បើកទ្វារ នៃ សន្តជន និង វិរបុរស ចេញពីប្រភព ជីវនៈ និង រយៈពេលជំរុញទៅមុខ ហើយ ធ្វើអោយរញ្ជួយ នៃមនុស្សជាតិ។ ក៏ដូចគ្នានឹង សាសនាថាមវន្តដែរ : - សាសនាអច្ឆិរអាថ៌កំបាំងធំៗ - រុករានចូលទៅក្នុង ជិវនៈ នៃសេចក្តីស្រឡាញ់, ដឹកនាំព្រលឹង ហួសពីខ្លួនឯងទៅទៀត សំរាប់ ការពារ និង ថ្នាំខ្លួនឯង ប្រឆាំងនឹង គំនិត បំផ្លាញ មាននៅក្នុងសេចក្តី

ស្លាប់ និង ធានា នូវការរក្សាខ្លួនអោយបានគង់វង់។ សាសនាថាមវន្ត ស្រវាចាប់ នូវការប៉ះទង្គិច ជាមួយនឹងរយៈពេល នៃការបង្កើត, បញ្ចេញឡើង ជាការពិសោធភ្លាមដែលជា ព្រលឹងអាថ៌កំបាំងទិព្វ និង អាទិទេព។

នៅទីបញ្ចប់ សីលធម៌បើកទ្វារ ក៏ដូច សាសនាបើកទ្វារ, សិល្បៈពិតប្រាកដដែរ កំណត់ ស្របផ្សំដោយថៃដន្យភ្លាមជាមួយនឹងសេចក្ដីពិត។ ជា ការបង្ហាញ នៃការពិត នោះឯង, ចក្ខុវិស័យផ្ទាល់មួយ ដែលបង្ហាញ នូវអ្វីដែលជាអ្វីលើសពីនិមិត្តសញ្ញាមានប្រយោជន៏។

បើសិនជាសម្លេង របស់លោក Bergson វាមិនឮសូរ នៅក្នុង វប្បធម៌ និង សម័យកាលរបស់គាត់, យ៉ាងហោចណាស់ ទស្សនវិជ្ជានេះ ជាការបំផុសគំនិត អាថ៌កំបាំង យកមកបំភ្លឺ នូវចិត្ត តាមពាក្យសំដីសាមញ្ញច្បាស់លាស់ មានខ្លឹមសារ និង សំដៅទៅលើ ការពិសោធន៏ នៃបរមត្ថវិជ្ជាទាំងមូល។ តើវាមិនជា ទស្សនវិស័យ សំរាប់ពិចារណា នោះទេឬ ? នៅក្នុង បំណង តាមការប្រឹងប្រែង នៃ អព្ភន្តរញ្ញាណ និង ស្របជាមួយវាតែម្ដង។



## អារម្ភកថា

នៅពេលខាងមុខទៀត យើងនឹងលើកយក ទស្សនវិទូ Comte, Descartes និង Hegel មកបង្ហាញបន្ត ក្នុងឈុត នៃការសិក្សា របស់យើង។ ដូចអ្នកអានដឹងស្រាប់ហើយថា ទស្សនវិជ្ជា មាននានាភាព នៃការត្រិះរិះច្រើនណាស់ ដែល នាំអោយមាន ន័យខុសៗគ្នា ទៅលើពាក្យនិមួយៗ។ ដូច្នេះ ការស្វែងរក និយមន័យ សាមញ្ញ ដើម្បីស្រួលចាំ និង យល់ ជាគោលដៅ នៃការសិក្សា របស់យើង ជាពិសេស រកន័យ ខ្មែរ ដែលមានដូច មកធ្វើជាការប្រៀបធៀប។ ការខ្វះ ខាត របស់យើង ក្នុងការសាកល្បងនេះ គឺ ជាការអភ័យ ទោសពីសំណាក់អ្នកអាន ដែលមានវិជ្ជា ទស្សនវិជ្ជាជ្រៅជ្រះ ឬ មានការចេះដឹងខ្ពង់ខ្ពស់។ ម្យ៉ាងមួយទៀត ការសាក ល្បងនេះ មិនមែនជា ការស្វែងរក នៃតួនាទី ជាអ្នកចេះ ដឹង ខាងទស្សនវិជ្ជា ឬ ជា បញ្ញាវន្ត នោះទេ, វាជា ការសិក្សា សំរាប់ខ្លួនឯងផ្ទាល់ ដែលជា ឥតរជន មួយរូប ចង់ចេះដឹង និង ចង់ចែកចំណេះដឹងដល់ជនដទៃ។ ដូចជាសំនួរសួរថា « អ្វីដែលខ្ញុំដឹង ? »